Australian Government
Department of Social Services



# អំពើហិង្សាក្នុងគ្រួសារ និងទិដ្ឋាការដៃគូ

## អ្នកកាន់ទិដ្ឋាការដៃគូ មិនត្រូវតែរក្សាការរស់នៅក្នុងទំនាក់ទំនងដែលរំលោភបំពានដើម្បីឲ្យបានស្នាក់នៅក្នុងប្រទេសអូស្ត្រាលីនោះឡើយ

នៅប្រទេសអូស្ត្រាលី អំពើហិង្សាតាមផ្ទះ និងក្នុងគ្រួសារមិនទទួលយកបានទេ។

ដៃគូ សមាជិកគ្រួសារ ឬជនផ្សេងទៀតក្នុងសហគមន៍ មិនអាចគម្រាមកំហែងដល់ស្ថានភាពនៃទិដ្ឋាការរបស់អ្នកបានឡើយ។

ប្រសិនបើអ្នកកាន់ទិដ្ឋាការដៃគូបណ្ដោះអាសន្ន (ថ្នាក់រង 300, 309 ឬ 820) ហើយទទួលរងនូវអំពើហិង្សាក្នុងគ្រួសារ ហើយទំនាក់ទំនងរបស់អ្នកបានចប់ គឺមានមាត្រាច្បាប់នៅក្នុងច្បាប់អន្តោប្រវេសន៍របស់ប្រទេសអូស្ត្រាលី ដែលអនុញ្ញាតឲ្យអ្នកបន្តដាក់ពាក្យសុំយកទិដ្ឋាការដៃគូអចិន្ត្រៃយ៍ (ថ្នាក់រង 100 ឬ 801) បាន។

ប្រសិនបើអ្នក ឬជនណាម្នាក់ដែលអ្នកស្គាល់ស្ថិតនៅក្នុងសភាពគ្រោះថ្នាក់ សូមទូរស័ព្ទទៅប៉ូលីសលេខ **000**។
ប៉ូលីសនៅប្រទេសអូស្ត្រាលីមានសុវត្ថិភាព ហើយអាចទុកចិត្តបាន។

សម្រាប់ការប្រឹក្សាយោបល់ និងការផ្គត់ផ្គង់ជាសម្ងាត់ ហើយឥតគិតថ្លៃ សូមទូរស័ព្ទ 1800 RESPECT លេខ **1800 737 732**។

ប្រសិនបើអ្នកត្រូវការអ្នកបកប្រែភាសាដោយឥតគិតថ្លៃ សូមទូរស័ព្ទលេខ **131 450**។

## នៅក្នុងស្ថានភាពបែបណាក៏ដោយ រដ្ឋាភិបាលអូស្ត្រាលីមិនអត់ឱនចំពោះអំពើហិង្សាតាមផ្ទះ និងក្នុងគ្រួសារឡើយ

អំពើហិង្សាតាមផ្ទះ និងក្នុងគ្រួសារគឺជាបទល្មើសប្រឆាំងនឹងច្បាប់។ ជនដែលប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារអាចជាប់ពន្ធនាគារ ទោះបីអ្នកនោះជាបុរស ឬស្ត្រីក៏ដោយ។

អំពើហិង្សាតាមផ្ទះ និងក្នុងគ្រួសារគឺជាអំពើប្រព្រឹត្ត ឬការគម្រាមកំហែងដែលមានបំណងដើម្បីត្រួតត្រាលើដៃគូជាបុរស ឬស្ត្រីដោយបង្កឲ្យមានការភ័យខ្លាច ឬក៏ការគម្រាមកំហែងដល់សុវត្ថិភាព ឬសុខុមាលភាពរបស់ពួកគេ។

## ជនណាម្នាក់ដែលទទួលរងនូវអំពើហិង្សាតាមផ្ទះ និងក្នុងគ្រួសារនៅក្នុងប្រទេសអូស្ត្រាលីអាចទទួលការគាំពារពីសេវាជំនួយបាន

អ្នកអាចទទួលការគាំពារបាន ទោះជាអ្នកកាន់ទិដ្ឋាការប្រភេទណាក៏ដោយ ឬមានស្ថានភាពអន្តោប្រវេសន៍យ៉ាងណាក៏ដោយ។

វាគ្មានបញ្ហាទេ ទោះជាទំនាក់ទាក់ទងបានចប់ទៅហើយក្ដី ឬក៏មិនទាន់ចប់ក្ដីក៏អ្នកនៅតែអាចទទួលការគាំពារបានដែរ។

**1800 RESPECT** គឺជាសេវាផ្ដល់ការប្រឹក្សាអំពីការរំលោភបំពានខាងផ្លូវភេទ អំពើហិង្សាតាមផ្ទះ និងក្នុងគ្រួសារ ទូទាំងប្រទេសរបស់ប្រទេសអូស្ត្រាលី។ សេវានេះផ្ដល់ព័ត៌មាន និងប្រឹក្សាតាមអ៊ីនធើណិត និងទូរស័ព្ទដោយសម្ងាត់ ហើយឥតគិតថ្លៃ។ អ្នកផ្ដល់ការប្រឹក្សានឹងស្ដាប់អ្នក ឆ្លើយសំណួរ និងអាចបញ្ជូនអ្នកទៅសេវាជំនួយផ្សេងៗទៀតនៅតាមតំបន់ដែលអ្នករស់នៅ។

សូមទូរស័ព្ទលេខ **1800 737 732** ឬបើកចូលវិបសាយរបស់ 1800 RESPECT នៅត្រង់ **www.1800RESPECT.org.au** ។

## តើអ្នកត្រូវការអ្នកបកប្រែភាសាឬទេ?

សូមទូរស័ព្ទទៅសេវាបកប្រែភាសាសរសេរ និងនិយាយ (TIS) ដោយឥតគិតថ្លៃ លេខ **131 450**។ TIS អាចជួយអ្នកឲ្យប្រាស្រ័យទាក់ទងជាមួយសេវាផ្សេងៗទៀតបាន។ TIS មិនផ្ដល់ការប្រឹក្សាទេ។

## សម្រាប់ព័ត៌មានបន្ថែមស្ដីពីមាត្រាច្បាប់ចែងពីអំពើហិង្សាក្នុងគ្រួសារ

រកមើលតាមការតភ្ជាប់ទៅកាន់សន្លឹកព័ត៌មានលេខ 38 លើវិបសាយរបស់ក្រសួងអន្តោប្រវេសន៍ និងការពារព្រំដែន (Department of Immigration and Border Protection) នៅត្រង់ **www.border.gov.au** ។